ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ៣១ ត្រីមាសទី០២ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៣៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ២២ រូប ៣៧២៥

១-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៣៧ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំដល់លោក **អ៊ុក រង្សី** (OUK REANGSEY) ជនជាតិខ្មែរ សញ្ជាតិខ្មែរ បច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ៣៧២៧

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៣៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ចំពោះ មន្ត្រីពន្ធនាគារខេត្តមណ្ឌលគិរី ៣ រូប ៣៧២៨

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ចំពោះ មន្ត្រីរាជការនៃសាលាខេត្តត្បូងឃ្មុំ ១៥រូប ៣៧២៩

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ចំពោះ មន្ត្រីរាជការនៃសាលាខេត្តរតនគិរី ១៧រូប ៣៧៣០

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ អស់លោក និងលោកស្រី ចំនួន ៥២ រូប ៣៧៣១

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់នាយទាហាន នាយទាហានរង នៃកងយោធពលខេមរភូមិន្ទ ៤រូប ៣៧៣៣

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការក្រសួងសុខាភិបាល ចំនួន ៩រូប ៣៧៣៤

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការទីស្តីការគណៈរដ្ឋមន្ត្រី ២០ រូប ៣៧៣៥

២-៤-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៤២២/៣៤៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ ៣៤ រូប ៣៧៣៦


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


៣១-៥-២០២២ -អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ៣៧៣៨

៣១-៥-២០២២ -អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ៣៧៤៤

៥-៥-២០២២ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៥៣

៥-៥-២០២២ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៥៥

៥-៥-២០២២ -អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៣៧៥៧

៥-៥-២០២២ -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៣៧៥៨

៥-៥-២០២២ -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៧៥៩

៦-៥-២០២២ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៦៤

៦-៥-២០២២ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៧៦៦

៦-៥-២០២២ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៦៨

៦-៥-២០២២ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៧៧០

៦-៥-២០២២ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពី ការតែងតាំងអគ្គនាយក នៃសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ ៣៧៧១


## III ~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


៨-៦-២០២២ -ប្រកាសលេខ ៤១១ សហវ.ប្រក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣៧៧២

១៣-៦-២០២២ -ប្រកាសលេខ ៤១៦ សហវ.ប្រក ស្តីពី ការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្ររដ្ឋ ៣៧៩២


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


១០-៥-២០២២ -ប្រកាសលេខ ១៧៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហេ យី ថេកណូឡូជី (ខេមបូឌា) ព្រីនធីង & ភែកឃិជីង ឯ.ក បង្កើតរោងចក្រ ផលិតសម្ភារវេចខ្ចប់ កេសក្រដាសកាតុង ប្រអប់ ថង់ប្លាស្ទិក និងបោះពុម្ពលើសម្ភារវេចខ្ចប់ ៣៧៩៥

២០-៥-២០២២ -ប្រកាសលេខ ១៩៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រ៉ុង ជីន ស៊ុ ស៊ី សេរ៉ាមិច ឯ.ក បង្កើតរោងចក្រ ផលិតឥដ្ឋការ៉ូគ្រប់ប្រភេទ ៣៧៩៨

២០-៥-២០២២ -ប្រកាសលេខ ១៩៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាឡេហ្គា ហ្គាមិន ហ្វេកធើរី ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨០១

២៤-៥-២០២២ -ប្រកាសលេខ ១៩៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុន តឺ ហ្គាមិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨០៤

២៤-៥-២០២២ -ប្រកាសលេខ ១៩៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វំម៉ាត (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨០៧

២៤-៥-២០២២ -ប្រកាសលេខ ១៩៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡាមូរអេស ឡៃថ៍ អេន ធើប្រាយ ឯ.ក បង្កើតរោងចក្រ ផលិត និងផ្គុំដំឡើងអំពូលភ្លើងពណ៌សម្រាប់តាំងលម្អគ្រប់ប្រភេទ ៣៨១០

២៤-៥-២០២២ -ប្រកាសលេខ ២០០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាញ ហ្វសស៍ ស្ពតធីង ហ្គូដ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៨១៣

២៤-៥-២០២២ -ប្រកាសលេខ ២០១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសវែលហ្វីត (ខេមបូឌា) បង្កើតរោងចក្រ ផលិតតំណបំពង់ដែកទីប ៣៨១៦

២៤-៥-២០២២ -ប្រកាសលេខ ២០២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផូឡារីស អឺភែរឹល ឯ.ក បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ និងផលិតម៉ាស់គ្រប់ប្រភេទ ៣៨១៩

២៥-៥-២០២២ -ប្រកាសលេខ ២០៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីនថាម (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតដើមណូអែល និងអំពូលភ្លើងលម្អគ្រប់ប្រភេទ ៣៨២២


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


២០-៧-២០២១ -ប្រកាសលេខ ០៦៨៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៦៨៤ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨២៥

២០-៧-២០២១ -ប្រកាសលេខ ០៧០៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧០៤ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨២៩

២០-៧-២០២១ -ប្រកាសលេខ ០៧០៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧០៥ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨៣៣

២០-៧-២០២១ -ប្រកាសលេខ ០៧០៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧០៦ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨៣៧

២០-៧-២០២១ -ប្រកាសលេខ ០៧០៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧០៨ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨៤១

២០-៧-២០២១ -ប្រកាសលេខ ០៧១០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧១០ រថ.អប្រក.លអ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១ ៣៨៤៥

# ព្រះរាជក្រឹត្យ

នស/រកត/០៤៤៤/៣៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **គុល** | **ប៊ុនតាត** | អត្តលេខ ០២៥២៩០ |
| ២-វរសេនីយ៍ឯក | **ប្រាជ្ញ** | **សំអាន** | អត្តលេខ ០១៤២៦១ |
| ៣-វរសេនីយ៍ឯក | **ព្រុំ** | **ស៊ីថា** | អត្តលេខ ០៤៣១៦៦ |
| ៤-វរសេនីយ៍ឯក | **លី** | **កញ្ញារិទ្ធិ** | អត្តលេខ ១៩២៣០១ |
| ៥-វរសេនីយ៍ឯក | **ខ្សៃ** | **ឡុន** | អត្តលេខ ១៤៥៤៥៥ |
| ៦-វរសេនីយ៍ឯក | **ចាយ** | **សម្បត្តិ** | អត្តលេខ ០៤៥៨៥៨ |
| ៧-វរសេនីយ៍ឯក | **ជុំ** | **សោភ័ណ្ឌ** | អត្តលេខ ១៤៥៤៥១ |
| ៨-វរសេនីយ៍ឯក | **ឃិន** | **សេកហុង** | អត្តលេខ ០៥០២៩១ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៩-វរសេនីយ៍ឯក | **ឡូន ម៉ុនថាវី (នារី)** | | អត្តលេខ ១៧៧១៨០ |
| ១០-វរសេនីយ៍ឯក | **ទ៉ូច** | **ស៊ីឃាង** | អត្តលេខ ០១១៤៨០ |
| ១១-វរសេនីយ៍ឯក | **មាន** | **ម៉ិនឡី** | អត្តលេខ ០៤៨៤៣៦ |
| ១២-វរសេនីយ៍ឯក | **ទូច** | **មិថុល** | អត្តលេខ ០៥៨៤៣៦ |
| ១៣-វរសេនីយ៍ឯក | **ព្រឿង** | **គីន** | អត្តលេខ ០១៤០៧៥ |
| ១៤-វរសេនីយ៍ឯក | **ចក់** | **ស៊ីថាច** | អត្តលេខ ១០០៣៥២ |
| ១៥-វរសេនីយ៍ឯក | **អេន** | **ស៊ីនីន** | អត្តលេខ ១៣៣៨២១ |
| ១៦-វរសេនីយ៍ឯក | **សាវ៉ាយ** | **ចាន់ថាច** | អត្តលេខ ០២៧៣១៨ |
| ១៧-វរសេនីយ៍ឯក | **គីម** | **សុភាព** | អត្តលេខ ០៧៨១៨៥ |
| ១៨-វរសេនីយ៍ឯក | **អេង** | **សុគី** | អត្តលេខ ១៩៨៤៤៨ |
| ១៩-វរសេនីយ៍ឯក | **ពៅ** | **ផុនសុផារ៉ា** | អត្តលេខ ០២៧២០៤ |
| ២០-វរសេនីយ៍ឯក | **ឈុន** | **វណ្ណា** | អត្តលេខ ០១៤៨៣៣ |
| ២១-វរសេនីយ៍ឯក | **ខង** | **ណារ៉េន** | អត្តលេខ ០១៤៧០៩ |
| ២២-វរសេនីយ៍ឯក | **អ៊ុក** | **ស៊ីម៉ុត្ថា** | អត្តលេខ ០៤២៦២០ |

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស.រកត.០៧២២.៣៣៥

[signature]

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

[signature]

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** អនុញ្ញាតឲ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំដល់លោក **អ៊ុក រង្សី** (OUK REANGSEY) ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០២ ទីកន្លែងកំណើតទីក្រុងអោសប៊ួគ (Augsburg) សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខា)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣៧.២២០៤.៣៣៩

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

(ហត្ថលេខា និងត្រា)

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៣៨

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស ចំពោះមន្ត្រីពន្ធនាគារខេត្តមណ្ឌលគិរី ៣រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១-ឧត្ដមអគ្គានុរក្សថ្នាក់លេខ២ **អាន គឹមឡេង**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១-ឧត្ដមអគ្គានុរក្សថ្នាក់លេខ២ **អ៊ិន សុវណ្ណ**

២- ឧត្ដមអគ្គានុរក្សថ្នាក់លេខ៣ **ឡុង គុល**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជឲ្យគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

ចារណ. ២២០៤.៣៤០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៣៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ផ្តល់**

គ្រឿងឥស្សរិយយស ចំពោះមន្ត្រីរាជការនៃសាលាខេត្តត្បូងឃ្មុំ ១៥រូបៈ

ក-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម **ប្លាង វន្នី**
២-លោក **គីម វិបុល**
៣-លោក **ហាស់ ពណ្ណរិទ្ធ**

ខ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម **យីន គីមហ៊ន**
២-ឯកឧត្តម **ឯម ដេត**
៣-ឯកឧត្តម **គល់ យ៉ាត**
៤-ឯកឧត្តម **សោម សាំង**
៥-ឯកឧត្តម **ចេន ចាន់ថន**
៦-ឯកឧត្តម **ហួត នន់**
៧-លោកជំទាវ **ខៀវ សាមួន**

គ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-លោក **វ៉ាន់ វុធ**
២-លោកស្រី **ហុង ដានីញ៉ា**

ឃ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១-ឯកឧត្តម **ឆាយ ទីប៉ា**
២-ឯកឧត្តម **សាំង ស៊ីមឿន**
៣-លោកស្រី **ទឹង សំអាត**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ហ.ត.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣រស.២២០៤.៣៤១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤៥៥/៣៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស ចំពោះមន្ត្រីរាជការនៃសាលាខេត្តរតនគិរី ១៧រូប៖

ក-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-ឯកឧត្តម **ស៊ឹម សនឡៃ**
២-ឯកឧត្តម **ហែម វណ្ណថន**
៣-ឯកឧត្តម **ហេង ប៊ុនថាន់**
៤-លោក **សេក ហៃ**
៥-លោក **ផាត់ សុភា**

ខ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១-ឯកឧត្តម **សុខ ហាម**
២-លោក **ហេង ប៊ុន្នី**
៣-លោកស្រី **សារ ស៊ីវត្ថា**
៤-លោក **សុខ លី**
៥-លោក **ហ៊ិត ហ៊ីយ**
៦-លោក **រស់ ឡាង**
៧-លោក **កែវ ពៅ**
៨-លោក **រម៉ាម ពុញ**
៩-លោក **ឃុំ សាខន**

គ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១-លោក **មួង មករា**
២-លោកស្រី **សុវណ្ណ សារុន**
៣-លោកស្រី **ណាន ចន្ទី**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចរស. ៥៥០៤. ៣៤៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ជូន**

ក-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-លោក **សុច ពិសី**
២-លោក **អ៊ីង បូរ៉ា**

ខ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-លោក **ម៉ក់ សម្បត្តិ**
២-លោក **ឆោម ក្រិត្យ**
៣-លោក **ហាយ ចន្ទាត់**

គ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

១-លោក **ថន ថាវុទ្ធា**
២-លោក **ហែម សារិទ្ធ**
៣-លោក **ឫ សំអូន**
៤-លោក **លឹម សុភាព**
៥-លោក **ភឹម ថា**
៦-លោក **រាជ បុន**
៧-លោក **ហ៊ឹង សារ៉ា**
៨-លោក **ម៉ោង រស់**
៩-លោកស្រី **ហ៊ុត ចាន់បូរ៉ា**
១០-លោក **ប៉ុល សារិត**
១១-លោក **សួស សារិទ្ធ**
១២-លោកស្រី **សូ ថាវី**
១៣-លោកស្រី **សូ សយ**
១៤-លោក **រស់ សាដែន**
១៥-លោកស្រី **មាស រ៉ាវី**
១៦-លោក **ម៉ុក សុវណ្ណ**
១៧-លោក **ទូត នៅ**
១៨-លោក **អ៊ិក មាលជី**

ឃ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១-លោក **ស៊ូ ម៉ុល**
២-លោក **អេង សុវណ្ណ**
៣-លោក **ណុប ចំរើន**
៤-លោក **ម៉ែន សារ៉ាន់**
៥-លោក **ជួន ចាន់ឫទ្ធី**
៦-លោក **ជូ ខេមរិទ្ធ**
៧-លោក **ព្រំ សារិន**
៨-លោកស្រី **ពេជ្រ ចាន់លីន**
៩-លោក **ភេ គង់**
១០-លោក **ឆាយ ភារិត**

១១-លោក **សុខ សារ៉ូត**
១២-លោក **ប៊ឹង លំអង**
១៣-លោក **ជុំ ស៊ីថា**
១៤-លោក **វង សាម៉េ**
១៥-លោកស្រី **កែន សារុំ**
១៦-លោក **សំ ឈី**
១៧-លោកស្រី **ឡឹក សុខា**
១៨-លោក **វ៉ា វុទ្ធី**
១៩-លោក **ព្រីង ណេន**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបទ្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៧៩ស. ២២០៤-៣៤៣

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស ដល់នាយទាហាន នាយទាហានរង នៃកងយោធពលខេមរភូមិន្ទ ៤រូប៖

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | ឡេង វណ្ណា | អត្តលេខ ០១៩៣៥០ |
| ២-ឧត្តមសេនីយ៍ត្រី | រស់ សារ៉េត | អត្តលេខ ០០២៦១៣ |
| ៣-វរសេនីយ៍ឯក | ចេនឡា រដ្ឋា | អត្តលេខ ០៤៧៨៧៧ |
| ៤-វរសេនីយ៍ឯក | ស មករា | អត្តលេខ ០៤៨៤១៦ |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរស.២២០៤.៣៤៤

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការក្រសួងសុខាភិបាល ចំនួន ៩រូប ៖

ក-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ**ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តមវេជ្ជបណ្ឌិតឯកទេស **គាន់ សុគុន**
២- ឯកឧត្តមសាស្ត្រាចារ្យរង **ទូច សុក្រិត**
៣- លោកសាស្ត្រាចារ្យរង **គីម ឈួង**
៤- លោក **ឯក សុនសត្យា**
៥- លោកសាស្ត្រាចារ្យ **ដួង ប៊ុណ្ណ**
៦- ឯកឧត្តម **លឹម ហួរ**

ខ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- លោកសាស្ត្រាចារ្យជំនួយ **ទូច យុន**
២- លោកសាស្ត្រាចារ្យជំនួយ **ខាត់ឌុន តារាផល**
៣- លោកវេជ្ជបណ្ឌិត **ជួន ម៉ានី**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៦៨.៦២០៤.៣៤៥

ហ.ត.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៤៤

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការទីស្ដីការគណៈរដ្ឋមន្ត្រី ២០រូប៖

ក-គ្រឿងឥស្សរិយយស**ជាតូបការ**

១-ឯកឧត្ដម **អាន ជាលី**
២-ឯកឧត្ដម **ថាវ គីមឡុង**
៣-ឯកឧត្ដម **សូ សីហា**

ខ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្ដម **ជួង តារា**
២-ឯកឧត្ដម **ប៊ិន ប៊ុនធាត**
៣-ឯកឧត្ដម **សេត មូហាំម៉ាត់ស៊ីស**
៤-ឯកឧត្ដម **សំ ប៊ុនណា**
៥-ឯកឧត្ដម **ស៊ុន ប៊ុល**

គ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្ដម **គីមរ័ត្ន វិសិដ្ឋ**
២-ឯកឧត្ដម **អ៊ឹម ស៊ីថុល**
៣-ឯកឧត្ដម **សូ សុខ**
៤-ឯកឧត្ដម **យិន យុនផយ**
៥-ឯកឧត្ដម **សៅ ផល្លា**

ឃ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-លោកជំទាវ **សេង សុមេធា**
២-ឯកឧត្ដម **ជោង សុជាតិ**

ង-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-ឯកឧត្ដម **អេង កុកថាយ**
២-ឯកឧត្ដម **គង់ ច័ន្ទវាសនា**
៣-ឯកឧត្ដម **ម៉ាង ផៃណាំ**
៤-ឯកឧត្ដម **ស៊ា មៅ**

ច-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

-ឯកឧត្ដម **តូច វ៉ាំម៉ូរី**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

៣៦៨. ២២០៤.៣៤៦

ហ.ស.

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២២/៣៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ ៣៤រូប៖

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **ហាប់ អ្វមាលី**
២- ឯកឧត្តម **សឹម សុខព្រី**
៣- ឯកឧត្តម **គីម សេរីវុធ**
៤- លោក **អ៊ុង វណ្ណា**
៥- លោក **អ៊ែ គីមឈាង**
៦- លោក **គា សុធី**
៧- លោក **គីម វិបុល**

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តមបណ្ឌិត **សុខ សារាវុឌ្ឍ**
២- ឯកឧត្តម **ចុង ផែត**
៣- លោក **កែវ សិគុណ**
៤- លោក **ឡូន ពេជ្រនិមិត្ត**
៥- លោក **ផេង សុផាណារម្យ**
៦- លោកស្រី **រស់ ម៉ាលីស**
៧- លោក **ខង ចន្ថា**
៨- លោកស្រី **រួល ខេដា**
៩- លោកស្រី **គា ចាន់បូរ៉ា**
១០- លោក **ម៉ប់ ធីរិត**
១១- លោក **ចិន ជីម**
១២- លោក **សំ ឌី**

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

ឯកឧត្តម **គុយ ឆាយ**

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

លោកស្រី **ទ្រី គីមលី**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោក | ជា | សែម | ៦- | លោក | ហង្ស | សាវ៉ន |
| ២- | លោក | ឃួន | លីនទី | ៧- | លោក | ព្រំ | ចាន់ថា |
| ៣- | លោក | ស៊ីយ៉ុន | សុចិត្រ | ៨- | លោកស្រី | ម៉ា | ច័ន្ទធីតា |
| ៤- | លោក | ស្រ៊ុន | ពុទ្ធី | ៩- | លោក | ស៊ិន | សុផា |
| ៥- | លោក | ចាន់ | បុលណា | ១០- | លោក | លាន | ភិរុណ |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោក | បុណ្ណាង | ស៊ីដានីត | ៣- | លោកស្រី | ធី | សុផារី |
| ២- | លោក | ង្វួន | មង្គល | | | | |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសំបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣១៧.២២០៤.៣៤៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលសរសេរជាអក្សរកាត់ថា **ក.ជ.ប.ស.** ដើម្បីសិក្សាស្រាវជ្រាវនិងអភិវឌ្ឍបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ច

**មាត្រា២ .-**

**គ.ជ.ប.ស.** មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| ៥- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | អនុប្រធានប្រចាំការ |
| ៦- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| ១៧- អគ្គលេខាធិការនៃគណៈវិស្វករកម្ពុជា | សមាជិក |
| ១៨- អគ្គលេខាធិការនៃគណៈស្ថាបត្យករកម្ពុជា | សមាជិក |
| ១៩- អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ២០- អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១- អគ្គនាយកមន្ទីរពិសោធន៍ជាតិសំណង់ | សមាជិក |
| ២២- តំណាងគ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានស្រាវជ្រាវពាក់ព័ន្ធមួយចំនួន | សមាជិក |
| ២៣- ប្រធានសមាគមអ្នកសាងសង់កម្ពុជា | សមាជិក |
| ២៤- ប្រធានសមាគមអ្នកអភិវឌ្ឍលំនៅឋានកម្ពុជា | សមាជិក |
| ២៥- ប្រធានសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា | សមាជិក |
| ២៦- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ | សមាជិកអចិន្ត្រៃយ៍។ |

ក្រៅពីសមាសភាពខាងលើ **គ.ជ.ប.ស.** អាចស្នើបន្ថែមសមាសភាពជាតំណាងក្រសួង ស្ថាប័ន ឬឥស្សរជននៃរាជរដ្ឋាភិបាល។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.ប.ស.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

**គ.ជ.ប.ស.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីដាក់ឱ្យប្រើបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់
- ផ្តល់យោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដាក់ឱ្យប្រើបទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀត ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា
- តាមដានការអនុវត្តនិងលើកសំណើឬផ្តល់យោបល់កែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់ដើម្បីឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់វិធាននិងផ្តល់គោលការណ៍ណែនាំក្នុងការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានស្រាវជ្រាវ អ្នកស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដើម្បីកៀរគរធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រសកម្មភាពសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកវិជ្ជាជីវៈ និងសាធារណជនអំពីបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការប្រព្រឹត្តទៅ

**មាត្រា៤ .-**

ប្រធាន **គ.ជ.ប.ស.** ដឹកនាំកិច្ចការទូទៅរបស់ **គ.ជ.ប.ស.**។ ក្នុងករណីអវត្តមាន ប្រធាន **គ.ជ.ប.ស.** អាចប្រគល់សិទ្ធិជូនអនុប្រធាន **គ.ជ.ប.ស.** ណាម្នាក់ឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ **គ.ជ.ប.ស.** ក្នុងឋានៈជាប្រធានស្តីទីរហូតដល់មានវត្តមានប្រធាន **គ.ជ.ប.ស.**។

អនុប្រធាន **គ.ជ.ប.ស.** អនុវត្តការងារតាមការកំណត់របស់ប្រធាន ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច។

**មាត្រា៥ .-**

**គ.ជ.ប.ស.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ជ.ប.ស.** អាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.ប.ស.**។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ជ.ប.ស.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ប.ស.**។

**គ.ជ.ប.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍ វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ដើម្បីចូលរួមប្រជុំពិគ្រោះយោបល់និងបំភ្លឺលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពជូនរាជរដ្ឋាភិបាល **គ.ជ.ប.ស.** អាចស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ផ្តល់ឯកសារ ទិន្នន័យ និងព័ត៌មាននានាដែលទាក់ទងនឹងការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍបទប្បញ្ញត្តិបច្ចេកទេសសំណង់របស់ **គ.ជ.ប.ស.** បាន។

**មាត្រា៦ .-**

**គ.ជ.ប.ស.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវដឹកនាំដោយអគ្គលេខាធិការ ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៧ .-**

**គ.ជ.ប.ស.** មានរូបសញ្ញាផ្ទាល់ខ្លួននិងមានសិទ្ធិប្រើត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការបំពេញការងារ។

រូបសញ្ញារបស់ **គ.ជ.ប.ស.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៨ .-**

**គ.ជ.ប.ស.** មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**គ.ជ.ប.ស.** មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននូវមូលនិធិដែលបានមកពីហិរញ្ញប្បទានឥតសំណង ជំនួយបច្ចេកទេស និងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

**រូបសញ្ញារបស់ គ.ជ.ប.ស.**

**អត្ថន័យនៃរូបសញ្ញា**
**ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់**

១. ពណ៌ខៀវ តំណាងឱ្យព្រះមហាក្សត្រ សាមគ្គីភាព ភាតរភាព សន្តិភាព និងភាពត្រជាក់ត្រជុំ រុងរឿងថ្កុំថ្កើង។

២. ពណ៌ក្រហមផ្នែកកណ្ដាល តំណាងឱ្យជាតិនិងស្មារតីអង់អាចក្លាហាន ពុះពារ គ្រប់ឧបសគ្គ ក្នុងការតាក់តែងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងការអនុវត្តច្បាប់។

៣. អក្សរពណ៌ស តំណាងឱ្យសាសនា ក្រមសីលធម៌ ចរិយាធម៌ និងការគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៤. ត្រៃវង្គ មានបួពណ៌ខៀវ ក្រហម ចារឹកដោយអក្សរពណ៌ស។ ពណ៌ទាំងបីតំណាងឱ្យបាវចនាជាតិ សាសនា ព្រះមហាក្សត្រ និងមានទម្រង់ជារង្វង់មូល តំណាងឱ្យការរួបរួមគ្នាតែមួយ។

៥. ព្រះវិស្សកម្មទេវបុត្រ ឬព្រះពិស្ណុការ គង់នៅលើព្រះបល្ល័ង្ក ព្រះហស្ដស្ដាំកាន់កូនប្រយោលតំណាងឱ្យបច្ចេកទេសសំណង់ទាំងឡាយ និងព្រះហស្ដឆ្វេងកាន់ក្បួនច្បាប់ តំណាងឱ្យអ្នកសម្រេចកិច្ចការសព្វបែបយ៉ាងផ្នែកខាងក្បួនច្បាប់សំណង់ និងសិល្បសាស្ត្រ។

៦. ក្បាច់ភ្ញីភ្លើង តំណាងឱ្យតេជានុភាព និងការផ្សាយនូវអំណាចក្នុងការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ ប្រកបដោយភាពរុងរឿង និងសុខដុមនីយកម្ម។

៧. ផ្ទៃខាងក្រោយពណ៌ផ្ទៃមេឃរាងមូល តំណាងឱ្យចក្រវាល លម្ហអាកាស និងភាពយុត្តិធម៌។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហៅថាអគ្គលេខាធិការដ្ឋាននៃ **ក.ជ.ប.ស.**។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ប.ស.** មានតួនាទីជាសេនាធិការឱ្យ **ក.ជ.ប.ស.** និងមានភារកិច្ចដូចតទៅៈ

- ផ្តួចផ្តើម សិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់
- លើកសំណើជូន **ក.ជ.ប.ស.** ដើម្បីពិនិត្យ សម្រេច ឬកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា ដើម្បីពិគ្រោះយោបល់ អភិវឌ្ឍ បញ្ជ្រាប ឬផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- តាមដាន ត្រួតពិនិត្យ និងធ្វើរបាយការណ៍វាយតម្លៃអំពីផលប៉ះពាល់និងប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិសម្រាប់ការអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរដ្ឋបាលទូទៅរបស់ **ក.ជ.ប.ស.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងធនធាននិងហិរញ្ញវត្ថុរបស់ **ក.ជ.ប.ស.**
- ធ្វើកំណត់ហេតុនិងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់ **ក.ជ.ប.ស.**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធាន **ក.ជ.ប.ស.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **ក.ជ.ប.ស.**។

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ប.ស.** ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

អគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមការបែងចែកការងារពីអគ្គលេខាធិការ។

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** មានសិទ្ធិប្រើត្រាដោយឡែក ដើម្បីបំពេញការងារ។

គំរូត្រារបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** គឺជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួង ស្ថាប័នដែលមានតំណាងជាអនុប្រធាននិងសមាជិកនៃ **គ.ជ.ប.ស.** អាចចាត់បញ្ជូនមន្ត្រីឱ្យមកបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** តាមសំណើរបស់ប្រធាន **គ.ជ.ប.ស.**។

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** អាចស្នើសុំមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

មន្ត្រីដែលត្រូវបានអនុញ្ញាតឱ្យមកបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** ត្រូវផ្អាកពីការងារនៅអង្គភាពដើម និងត្រូវបានរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង និងការចូលនិវត្តន៍ ព្រមទាំងរក្សាមុខតំណែងក្នុងអង្គភាពដើម។ ដោយឡែក ចំពោះមន្ត្រីរាជការដែលកាន់មុខតំណែងច្រើនត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយ។

**មាត្រា៦ .-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** មានរចនាសម្ព័ន្ធដូចតទៅ៖

- នាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រឿងផ្គុំសំណង់
- នាយកដ្ឋានបច្ចេកទេសភូតគព្ភសាស្ត្រ
- នាយកដ្ឋានសេវាកម្មសំណង់
- នាយកដ្ឋានស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង។

**មាត្រា៧ .-**

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ។

អនុប្រធាននាយកដ្ឋានត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៣
## ភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៩ .-**

នាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្ម ផ្គត់ផ្គង់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ **គ.ជ.ប.ស.**
- សម្របសម្រួលរៀបចំផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា និងពិធីការ
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង បោះពុម្ព រៀបចំការបណ្តុះបណ្តាល និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- តាមដាននិងវាយតម្លៃលើការអនុវត្តអនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ
- រៀបចំ គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.ជ.ប.ស.**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋានអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.ស.** និង **គ.ជ.ប.ស.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

**មាត្រា១០ .-**

នាយកដ្ឋានគ្រឿងផ្គុំសំណង់មានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់
- ផ្តួចផ្តើមនិងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់
- តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់ និងលើកសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- សិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកបន្ទុក និងផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់នាយកដ្ឋាន

- រៀបចំផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

**មាត្រា១១ .-**

នាយកដ្ឋានបច្ចេកទេសភូគព្ភសាស្ត្រមានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ មានជាអាទិ៍បទដ្ឋានដីគ្រឹះ បទដ្ឋានពង្រឹងគុណភាពដី បទដ្ឋានលំនឹងជម្រាល បទដ្ឋានជីកដី
- ផ្តួចផ្តើមនិងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ
- តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ និងលើកសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- សិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកបច្ចេកទេសភូគព្ភសាស្ត្រដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

**មាត្រា១២ .-**

នាយកដ្ឋានសេវាកម្មសំណង់មានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់ និងសំឡេង និងបទដ្ឋានបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ
- ផ្តួចផ្តើមនិងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់និងសំឡេង
- តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់និងសំឡេង និងបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត និងលើកសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់

- សិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់និងសំឡេង និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់និងសំឡេង និងបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកប្រព័ន្ធមេកានិក ផ្នែកប្រព័ន្ធអគ្គិសនី ផ្នែកប្រព័ន្ធទឹក ផ្នែកប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ផ្នែកប្រព័ន្ធអ៊ីសូឡង់និងសំឡេង ដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ និងបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

**មាត្រា១៣ .-**

នាយកដ្ឋានស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតងមានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ តាក់តែង ប្រមូល និងចងក្រងបទដ្ឋានបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ និងដោយយកចិត្តទុកដាក់ចំពោះជនមានពិការភាព កុមារ មនុស្សវ័យចាស់ និងសមភាពយេនឌ័រ
- ផ្តួចផ្តើមនិងលើកសំណើសុំការសម្រេចលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង
- តាមដាននិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង និងលើកសំណើសុំកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់
- សិក្សា ស្រាវជ្រាវ និងរៀបចំតាក់តែងគោលការណ៍ណែនាំអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតង
- រៀបចំផែនការ គម្រោង និងកម្មវិធីបណ្តុះបណ្តាលអំពីបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផ្នែកស្ថាបត្យកម្មនិងការអភិវឌ្ឍបៃតងដល់មន្ត្រីជំនាញ អ្នកវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានស្រាវជ្រាវ និងវិស័យឯកជនពាក់ព័ន្ធ និងបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងសេវាកម្មសំណង់ដទៃទៀត

- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១កើត ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

**គំរូត្រារបស់អគ្គលេខាធិការដ្ឋាននៃ ក.ជ.ប.ស.**



ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ ក.ជ.ប.ស.**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៥៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១២៤ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមការងារចាំបាច់

## សម្រេច

**មាត្រា១ :** តែងតាំងជំនួយការរាជបណ្ឌិត្យសភាកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. លោក | **ឧខ ភាឌីណាល់** | មានឋានៈស្មើ អគ្គនាយករង |
| ២. លោក | **ស្វ មេន** | មានឋានៈស្មើ អគ្គនាយករង ។ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១២៤ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមការងារចាំបាច់

## សម្រេច

**មាត្រា១ :** តែងតាំងលោកស្រី Gang Kyoung Hee ជាជំនួយការរាជបណ្ឌិត្យសភាកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ៖** ផ្ទេរ និងតែងតាំងមុខតំណែងលោកស្រីវរសេនីយ៍ឯក **ហោ សុភន** អត្តលេខ ៧៣៧៣៣៧ ជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:២៩៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់**វរសេនីយ៍ឯក** ដល់វរសេនីយ៍ទោ **រ៉េត ភូលីន** អត្តលេខ ៧៤៧៨៧ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍៥កើត ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែមេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា១..** បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និងពលទាហាន ចំនួន ១០២រូប ដែលដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

១- ឧត្តមសេនីយ៍ត្រី សួស នាង អត្តលេខ ០០០៦៨១ នាយរង ការិយាល័យទី៥ កងទ័ពជើងគោក
២- ឧត្តមសេនីយ៍ត្រី សុក សិត្ថា អត្តលេខ ០០២០២៩ នាយរង ការិយាល័យទី៥ កងទ័ពជើងគោក
៣- ឧត្តមសេនីយ៍ត្រី ស វណ្ណា អត្តលេខ ០១៦៨៦៤ នាយរង ការិយាល័យទី៥ កងទ័ពជើងគោក
៤- វរសេនីយ៍ឯក ប្រាក់ តារា អត្តលេខ ០២៩៦៧៣ នាយរង ការិយាល័យទី៤ កងទ័ពជើងគោក
៥- វរសេនីយ៍ឯក ហ៊ុំ វិសាល អត្តលេខ ០១៧២៤២ នាយរង ការិយាល័យទី២ កងទ័ពជើងគោក

ខ-មេដាយ**ប្រាក់ការងារ**

១- វរសេនីយ៍ទោ យិន ចន្ថា អត្តលេខ ១៥៧៨១៩ នាយរង ការិយាល័យទី៤ កងទ័ពជើងគោក
២- វរសេនីយ៍ទោ វ៉ាន់ សុខន អត្តលេខ ០៨១៤៧៣ នាយរងការិយាល័យទី២ កងទ័ពជើងគោក
៣- វរសេនីយ៍ទោ ម៉ែន សុខេង អត្តលេខ ២០៦៨៨១ នាយរងផ្នែកផែនការ ការិយាល័យទី៤ កងទ័ពជើងគោក
៤- វរសេនីយ៍ទោ ថា សៅស៊ែកក្រ អត្តលេខ ០៥៨៨២០ នាយរងផ្នែកលេខាធិការដ្ឋាន ការិយាល័យទី៥

| | | | | |
|---|---|---|---|---|
| ៥- | វរសេនីយ៍ត្រី | ថែម សុភ័ក្រ | អត្តលេខ ០៨៨៧០៨ | មេបញ្ជាការរង កងអនុសេនាធំដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក |
| ៦- | វរសេនីយ៍ត្រី | សុខ ប៉ាវ | អត្តលេខ ១០៦៦៨៨ | មេបញ្ជាការរង កងអនុសេនាធំដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក |
| ៧- | វរសេនីយ៍ទោ | ហេង សឿន | អត្តលេខ ០៨៨៥៦២ | នាយរងផ្នែកលេខាធិការដ្ឋាន ការិយាល័យទី៤ កងទ័ពជើងគោក |
| ៨- | វរសេនីយ៍ត្រី | អ៊ឹម សំអុន | អត្តលេខ ១៥១៩១៥ | នាយរងផ្នែកផែនការ ការិយាល័យទី៤ កងទ័ពជើងគោក |
| ៩- | វរសេនីយ៍ត្រី | គី សឿន | អត្តលេខ ០២៥៨២១ | ជំនួយការ ឯកឧត្តម ជ វណ្ណារិទ្ធ ការិយាល័យទី៤ កងទ័ពជើងគោក |
| ១០- | វរសេនីយ៍ត្រី | កៅ សុខុម | អត្តលេខ ០៧៩២០៥ | មេបញ្ជាការរង កងអនុសេនាធំដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក |
| ១១- | វរសេនីយ៍ត្រី | ជា សារ៉ុម | អត្តលេខ ០៨៩០៨៨ | មេបញ្ជាការ កងតូចទី២ ការិយាល័យទី៤ កងទ័ពជើងគោក |
| ១២- | វរសេនីយ៍ត្រី | សេង វីរ៉ាត់ | អត្តលេខ ០៧៣៨១៩ | មេបញ្ជាការ កងតូចទី៣ ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៣- | វរសេនីយ៍ត្រី | អ៊ុំ ណារុំ | អត្តលេខ ១៩១១១៨ | ជំនួយការផ្នែកយោធបរិក្ខារ ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៤- | វរសេនីយ៍ត្រី | ថា ច័ន្ទណារី | អត្តលេខ ០៨៨៦៩០ | នាយរងផ្នែកកិច្ចការនារី ការិយាល័យទី៥ |
| ១៥- | វរសេនីយ៍ត្រី | ម៉ៅ ដាលី | អត្តលេខ ០៥៩១០៧ | ជំនួយការ សិល្បៈយោធាភិរម្យ ការិយាល័យទី៥ |
| ១៦- | វរសេនីយ៍ត្រី | គី សុភារ៉ា | អត្តលេខ ០៧០៣១៩ | នាយរង ការិយាល័យទី៥ កងពលធំអន្តរាគមន៍លេខ២ |

គ-មេដាយ**សំរឹទ្ធការងារ**

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | ឈៀវ សុភ័ណ | អត្តលេខ ០៨៨៦៩៥ | ជំនួយការសិល្បៈយោធាភិរម្យការិយាល័យទី៥ |
| ២- | វរសេនីយ៍ត្រី | ឡឹង ប៊ុនធឿន | អត្តលេខ ១៦៣៥០៦ | នាយរងការិយាល័យរថក្រោះ កងពលធំអន្តរាគមន៍លេខ២ |
| ៣- | អនុសេនីយ៍ឯក | អាន ប៊ុនថន | អត្តលេខ ០៧៩១៧៩ | មេបញ្ជាការរង កងតូចទី២ ការិយាល័យទី៤ កងទ័ពជើងគោក |
| ៤- | អនុសេនីយ៍ឯក | ថា ទិត្យណារី | អត្តលេខ ១០៦៣០៧ | នាយរងផ្នែកបច្ចេកទេស ការិយាល័យទី៥ |
| ៥- | អនុសេនីយ៍ឯក | ផាត់ ផល្លា | អត្តលេខ ១០៨១៧៥ | ជំនួយការ សន្តិសុខផ្ទៃក្នុង ការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៦- | អនុសេនីយ៍ឯក | សេង គឹមកឿន | អត្តលេខ ១០៣៥១៧ | ជំនួយការ ការិយាល័យទី២ កងពលធំអន្តរាគមន៍លេខ២ |
| ៧- | អនុសេនីយ៍ឯក | គង់ រតនៈ | អត្តលេខ ០៦៦៩១៣ | ជំនួយការ បូកសរុប ការិយាល័យទី៣ កងពលធំអន្តរាគមន៍លេខ២ |
| ៨- | អនុសេនីយ៍ឯក | ថៃ រម្មី | អត្តលេខ ០៧០៣១០ | ជំនួយការ សិល្បៈ ការិយាល័យទី៥ កងពលធំអន្តរាគមន៍លេខ២ |
| ៩- | អនុសេនីយ៍ឯក | សុង សុខហេង | អត្តលេខ ០៨៦២២៧ | ជំនួយការ ការិយាល័យការពារអាកាស កងពលធំអន្តរាគមន៍លេខ២ |
| ១០- | អនុសេនីយ៍ឯក | សាត រ៉ាស៊ី | អត្តលេខ ២៣០០៨៨ | ជំនួយការ បច្ចេកទេសសំណង់ ការិយាល័យវិស្វកម្ម កងពលធំអន្តរាគមន៍លេខ២ |
| ១១- | អនុសេនីយ៍ឯក | ថាវ សាគូរ៉ា | អត្តលេខ ០៨៣៩៩៤ | ជំនួយការ ការិយាល័យរថក្រោះ កងពលធំអន្តរាគមន៍លេខ២ |
| ១២- | អនុសេនីយ៍ឯក | នី វ៉ាន | អត្តលេខ ១០២០៨៩ | ជំនួយការ សេនាធិការ វរសេនាតូចវិស្វកម្ម កងពលធំអន្តរាគមន៍លេខ២ |

| | | | | |
|---|---|---|---|---|
| ១៣- អនុសេនីយ៍ឯក | ឈាន សេរី | អត្តលេខ | ១០៣២៣៧ | គ្រូពេទ្យព្យាបាលជម្ងឺទូទៅ តិលានដ្ឋាន ការិយាល័យសុខាភិបាល កងពលធំអន្តរាគមន៍លេខ២ |
| ១៤- អនុសេនីយ៍ឯក | ភិន ដារ៉ូ | អត្តលេខ | ២០៤២៥៩ | នាយទាហាន ការិយាល័យបច្ចេកទេស កងពលធំអន្តរាគមន៍លេខ២ |
| ១៥- អនុសេនីយ៍ឯក | ធន់ បូណា | អត្តលេខ | ១០៣៩០២ | ជំនួយការ ឯកសារ ការិយាល័យទី៥ កងពលធំអន្តរាគមន៍លេខ២ |
| ១៦- អនុសេនីយ៍ឯក | ស សុវណ្ណ | អត្តលេខ | ០៦៨៨០០ | មេបញ្ជាការរង កងតូចទី៣ ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៧- អនុសេនីយ៍ឯក | ឈិន ភិរុណ | អត្តលេខ | ០៧៥៣៨១ | នាយហានាការិយាល័យទី៣ |
| ១៨- អនុសេនីយ៍ឯក | អ៊ឹម ដារ៉ាវុធ | អត្តលេខ | ០៨៨៧០០ | មេបញ្ជាការរង វរសេនាតូចឃ្លាំង ការិយាល័យទី៤ កងទ័ពជើងគោក |
| ១៩- អនុសេនីយ៍ឯក | ឱ សុផល | អត្តលេខ | ០៦៨៧៧៦ | មេបញ្ជាការរង កងអនុសេនាធំដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក |
| ២០- អនុសេនីយ៍ឯក | សឹម វ៉េនមុនី | អត្តលេខ | ០៦៦៨០២ | ជំនួយការផ្នែកផែនការ ការិយាល័យទី៤ កងទ័ពជើងគោក |
| ២១- អនុសេនីយ៍ឯក | ង៉ែត ចាន់ | អត្តលេខ | ០៨៨៧០៥ | ជំនួយការផ្នែកប្រេងឥន្ធនៈ ការិយាល័យទី៤ កងទ័ពជើងគោក |
| ២២- អនុសេនីយ៍ឯក | ឈួន ឈឿង | អត្តលេខ | ១០២១៨៤ | នាយរង ការិយាល័យទី៣ កងពលធំអន្តរាគមន៍លេខ២ |
| ២៣- អនុសេនីយ៍ឯក | សុខ សែន | អត្តលេខ | ១០២៨៥៤ | មេបញ្ជាការ កងអនុសេនាធំការពារ កងពលធំអន្តរាគមន៍លេខ២ |
| ២៤- អនុសេនីយ៍ឯក | កាន់ ខេមរា | អត្តលេខ | ០៧០១៨៥ | ជំនួយការ ហិរញ្ញវត្ថុ កងពលធំអន្តរាគមន៍លេខ២ |
| ២៥- អនុសេនីយ៍ឯក | គួច ជីផេង | អត្តលេខ | ២២៦០៤៩ | មេបញ្ជាការរង កងអនុសេនាធំទី២ កងពលធំអន្តរាគមន៍លេខ២ |
| ២៦- អនុសេនីយ៍ឯក | ដាំ ដារ៉ា | អត្តលេខ | ១០២៤២០ | មេបញ្ជាការរង កងអនុសេនាធំទី៣ កងពលធំអន្តរាគមន៍លេខ២ |
| ២៧- អនុសេនីយ៍ឯក | នាង ធុល | អត្តលេខ | ១០២៧២០ | មេបញ្ជាការ កងអនុសេនាធំទី១ វរសេនាតូចកាំភ្លើងធំ កងពលធំអន្តរាគមន៍លេខ២ |
| ២៨- អនុសេនីយ៍ឯក | ឡាត់ ធីន | អត្តលេខ | ០៦៨៨៥៩ | មេបញ្ជាការ កងអនុសេនាធំទី២ វរសេនាតូចស៊ើបការណ៍ កងពលធំអន្តរាគមន៍លេខ២ |
| ២៩- អនុសេនីយ៍ឯក | ព្រហ្ម រតនៈ | អត្តលេខ | ១៥៦៧០៨ | នាយរងលេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៣០- អនុសេនីយ៍ឯក | ភឿក រតនៈ | អត្តលេខ | ០៨៦៣៣០ | នាយរងការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៣១- អនុសេនីយ៍ឯក | ជ្រា ហុកហេង | អត្តលេខ | ១០៨០៨៨ | នាយរង ការិយាល័យហ៊ិកហ្វឺន កងពលធំអន្តរាគមន៍លេខ២ |
| ៣២- អនុសេនីយ៍ឯក | ប៊ូ ច័ន្ទសុទ្ធារិទ្ធ | អត្តលេខ | ០៦៦០១២ | ជំនួយការ ព័ត៌មានវិទ្យា ការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៣៣- អនុសេនីយ៍ឯក | ហេង គឹមស្រ៊ុន | អត្តលេខ | ០៧០៦៣១ | ជំនួយការ គោលនយោបាយ ការិយាល័យទី៥ កងពលធំអន្តរាគមន៍លេខ២ |
| ៣៤- អនុសេនីយ៍ឯក | សេង ពៅ | អត្តលេខ | ១០២៦០០ | មេបញ្ជាការរង វរសេនាតូចការពារអាកាស កងពលធំអន្តរាគមន៍លេខ២ |
| ៣៥- អនុសេនីយ៍ឯក | សេក សារឿន | អត្តលេខ | ១០២៥៨៦ | ជំនួយការ លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៣៦- អនុសេនីយ៍ឯក | អ៊ុំ វណ្ណៈ | អត្តលេខ | ១០២៧៩៩ | ជំនួយការ លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៣៧- អនុសេនីយ៍ឯក | ហាក់ ម៉េងហ៊ាន់ | អត្តលេខ | ១០២១៣៧ | ជំនួយការ លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៣៨- អនុសេនីយ៍ឯក | ព្រំ បុប្ផា | អត្តលេខ | ០៥៨៨២៧ | ជំនួយការ សិល្បៈយោធាភិរម្យ ការិយាល័យទី៥ |
| ៣៩- អនុសេនីយ៍ឯក | ស សារ៉ុម | អត្តលេខ | ២២១៧៤០ | ជំនួយការ សិល្បៈយោធាភិរម្យ ការិយាល័យទី៥ |

| | | | | |
|---|---|---|---|---|
| ៤០- អនុសេនីយ៍ឯក | សំ រតនៈ | អត្តលេខ | ១៣៦៦៣៤ | នាយរង ផ្នែករបាំបូរាណ សិល្បៈយោធាតិរម្យ ការិយាល័យទី៥ |
| ៤១- អនុសេនីយ៍ឯក | ហ៊ឹម កល្យាណ | អត្តលេខ | ០៤៨៧០១ | ជំនួយការ សិល្បៈយោធាតិរម្យ ការិយាល័យទី៥ |
| ៤២- អនុសេនីយ៍ទោ | ឆេង វិច្ឆិកា | អត្តលេខ | ១៦៨៤៧៨ | ជំនួយការផែនការ ការិយាល័យហ៊្វីកហ្វឺន កងពលធំអន្តរាគមន៍លេខ២ |
| ៤៣- អនុសេនីយ៍ទោ | មាស ភារុណ | អត្តលេខ | ១០២៣៨៨ | មេបញ្ជាការរង វរសេនាតូចវិស្វកម្ម កងពលធំអន្តរាគមន៍លេខ២ |
| ៤៤- អនុសេនីយ៍ទោ | ឌុច ផង់ស៊ីដា | អត្តលេខ | ១០២៦២៣ | មេបញ្ជាការរង វរសេនាតូចការពារអាកាស កងពលធំអន្តរាគមន៍លេខ២ |
| ៤៥- អនុសេនីយ៍ទោ | លាម លិះ | អត្តលេខ | ១៣១០៨៥ | ជំនួយការបុគ្គលិក វរសេនាតូចកាំភ្លើងត្បាល់ កងពលធំអន្តរាគមន៍លេខ២ |
| ៤៦- អនុសេនីយ៍ទោ | សៀក សំខាន់ | អត្តលេខ | ០៧០២៣៥ | ជំនួយការហិរញ្ញវត្ថុ វរសេនាតូចកាំភ្លើងត្បាល់ កងពលធំអន្តរាគមន៍លេខ២ |
| ៤៧- អនុសេនីយ៍ទោ | នូ ម៉ៅ | អត្តលេខ | ១០៣១៩២ | នាយរងការិយាល័យសុខាភិបាល កងពលធំអន្តរាគមន៍លេខ២ |
| ៤៨- អនុសេនីយ៍ទោ | ខៀវ សំណាង | អត្តលេខ | ១០២៦៩៨ | នាយកសិដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងពលធំអន្តរាគមន៍លេខ២ |
| ៤៩- អនុសេនីយ៍ទោ | តូច តុលា | អត្តលេខ | ២៣៥៣៥៥ | ជំនួយការ ឯកសារការិយាល័យទី៥ កងពលធំអន្តរាគមន៍លេខ២ |
| ៥០- អនុសេនីយ៍ទោ | ហេង សុវ៉ាតឌី | អត្តលេខ | ១៤៦១៨១ | ជំនួយការបុគ្គលិក វរសេនាតូចរថក្រោះលេខ ៦៥ កងពលធំអន្តរាគមន៍លេខ២ |
| ៥១- អនុសេនីយ៍ទោ | មាត់ គឹមសាង | អត្តលេខ | ១០២៩៧៩ | ជំនួយការប្រតិបត្តិការសឹក វរសេនាតូចកាំភ្លើងធំ កងពលធំអន្តរាគមន៍លេខ២ |
| ៥២- អនុសេនីយ៍ទោ | ផាត់ រតនា | អត្តលេខ | ២៣៥៣៦០ | មេបញ្ជាការរង វរសេនាតូចកាំភ្លើងត្បាល់ កងពលធំអន្តរាគមន៍លេខ២ |
| ៥៣- អនុសេនីយ៍ទោ | ហ៊ាត់ ម៉េង | អត្តលេខ | ១០៤១១១ | ជំនួយការសេនាធិការ វរសេនាតូចកាំភ្លើងត្បាល់ កងពលធំអន្តរាគមន៍លេខ២ |
| ៥៤- អនុសេនីយ៍ទោ | ហ៊ាន សំណាង | អត្តលេខ | ២១៦២០៣ | ជំនួយការ សន្តិសុខផ្ទៃក្នុង ការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៥៥- អនុសេនីយ៍ទោ | ហៃល សម្ផស្ស | អត្តលេខ | ១៥៧៣១១ | ជំនួយការផ្នែកដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក |
| ៥៦- អនុសេនីយ៍ទោ | ហួន ចាន់សេរីវ័ត្ន | អត្តលេខ | ១៣៣៨១៥ | នាយរងផ្នែកគោលនយោបាយ ការិយាល័យទី៥ |
| ៥៧- អនុសេនីយ៍ទោ | ស៊ា ប៊ុនគេង | អត្តលេខ | ២៣៣៤៧១ | ជំនួយការ ពេទ្យ កងពលតូចអន្តរាគមន៍លេខ៦ |
| ៥៨- អនុសេនីយ៍ទោ | សន វ៉ាន | អត្តលេខ | ២០១១២៧ | ជំនួយការ លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៥៩- អនុសេនីយ៍ទោ | ប៊ូ បឿន | អត្តលេខ | ០៧០៣៥៣ | ជំនួយការ លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៦០- អនុសេនីយ៍ទោ | ឆេង វិច្ឆិកា | អត្តលេខ | ១៦៨៤៧៨ | ជំនួយការ ផែនការ ការិយាល័យហ៊្វីកហ្វឺន កងពលធំអន្តរាគមន៍លេខ២ |
| ៦១- អនុសេនីយ៍ទោ | ទិត្យ សុផាត | អត្តលេខ | ១០២១៥៩ | មេបញ្ជាការ កងអនុសេនាធំទី១ វរសេនាតូចស៊ើបការណ៍ កងពលធំអន្តរាគមន៍លេខ២ |
| ៦២- អនុសេនីយ៍ទោ | អោក សុភក្តី | អត្តលេខ | ០៦៤៤៤៦ | មេបញ្ជាការរង កងអនុសេនាធំការពារ កងពលធំអន្តរាគមន៍លេខ២ |
| ៦៣- អនុសេនីយ៍ទោ | គង់ សុផល | អត្តលេខ | ១០៣២៣៤ | មេបញ្ជាការរង កងអនុសេនាធំការពារ កងពលធំអន្តរាគមន៍លេខ២ |

| | | | | |
|---|---|---|---|---|
| ៦៤- | អនុសេនីយ៍ទោ | សូ សំណាង | អត្តលេខ ១៦៣៩៣៧ | ជំនួយការសោធននិវត្តន៍ ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងកំពត |
| ៦៥- | អនុសេនីយ៍ទោ | ភួង សុផាវិសាល | អត្តលេខ ១៦៨៥៦៧ | ជំនួយការបុគ្គលិក លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ៣ |
| ៦៦- | អនុសេនីយ៍ត្រី | ទូច ច័ន្ទសុភាព | អត្តលេខ ០៨៣១៦៥ | ជំនួយការផ្នែកកិច្ចការនារី ការិយាល័យទី៥ |
| ៦៧- | អនុសេនីយ៍ត្រី | ស៊ុំ រិទ្ធី | អត្តលេខ ០៦៩៧៥០ | បុគ្គលិក លេខាធិការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ |
| ៦៨- | អនុសេនីយ៍ត្រី | ពក ស៊ីវន | អត្តលេខ ២៣៨៨០៦ | ជំនួយការបុគ្គលិក ការិយាល័យទី១ |
| ៦៩- | អនុសេនីយ៍ត្រី | ហាម ខេមរិន | អត្តលេខ ២៣៨០០១ | បុគ្គលិក តែងតាំងផ្លាស់ប្តូរ ការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៧០- | អនុសេនីយ៍ត្រី | ផា សុថា | អត្តលេខ ១០២២៩៧ | ជំនួយការអត្តសញ្ញាណប័ណ្ណ ការិយាល័យទី១ កងពលធំអន្តរាគមន៍លេខ២ |
| ៧១- | អនុសេនីយ៍ត្រី | លឹម រតនី | អត្តលេខ ១៩៣២៨៤ | ជំនួយការអគ្គអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុក្រសួងការពារជាតិ |
| ៧២- | នាយឯក | កែវ ម៉ានិច | អត្តលេខ ០៤៨៦៩២ | ជំនួយការផ្នែកកិច្ចការនារី ការិយាល័យទី៥ |
| ៧៣- | នាយចំណង់ | ជឹម ចាន់ណោត | អត្តលេខ ២២៧១៩២ | ជំនួយការផ្នែកកិច្ចការនារី ការិយាល័យទី៥ |
| ៧៤- | នាយចំណង់ | វន ដារ៉ា | អត្តលេខ ១៤៥៥៥៣ | ជំនួយការ ការិយាល័យទី៥ |
| ៧៥- | នាយចំណង់ | ឈាន ភារម្យ | អត្តលេខ ១០២១៧៦ | ជំនួយការ ប្រតិបត្តិការសឹក វរសេនាតូចស៊ើបការណ៍ កងពលធំអន្តរាគមន៍លេខ២ |
| ៧៦- | នាយចំណង់ | អុល វិរៈ | អត្តលេខ ២៣៨៣០៩ | ជំនួយការ បុគ្គលិក វរសេនាតូចស៊ើបការណ៍ កងពលធំអន្តរាគមន៍លេខ២ |
| ៧៧- | នាយចំណង់ | ធៀង កែវឡុង | អត្តលេខ ០៧០៧៦៨ | ជំនួយការ បុគ្គលិក កងឯកភាពហ្វឹកហ្វឺន កងពលធំអន្តរាគមន៍លេខ២ |
| ៧៨- | នាយចំណង់ | ញ៉ែត រិន | អត្តលេខ ១៨០៨៩១ | ជំនួយការ ផ្នែកសឹករងឈ្លកតំបន់ប្រតិបត្តិការសឹករងកំពត |
| ៧៩- | ព្រឹន្ទបាលឯក | សោ ចាន់ | អត្តលេខ ១០២៥៥០ | ជំនួយការបុគ្គលិក វរសេនាតូចបញ្ជូនសារ កងពលធំអន្តរាគមន៍លេខ២ |
| ៨០- | ព្រឹន្ទបាលទោ | កែន សាវុធ | អត្តលេខ ២៣៧៩៨៦ | ជំនួយការ បុគ្គលិក វរសេនាតូចកាំភ្លើងធំ កងពលធំអន្តរាគមន៍លេខ២ |
| ៨១- | ពលទោ | សួន ពិសី | អត្តលេខ ២៣០៤៥៣ | ជំនួយការផ្នែកកិច្ចការនារី ការិយាល័យទី៥ |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៩៨ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការថ្វាយនិងការប្រគល់មេដាយមុនីសារាភ័ណ្ឌ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១.**-បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១៥រូប ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅ វត្តយសមេត្រី ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល ចំណាយអស់ថវិកាចំនួន ៩៣៩ ១៤០ (ប្រាំបួនរយសាមសិបបីពាន់ មួយរយសែសិប) ដុល្លារអាម៉េរិកកន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម៖

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- ព្រះសិរីបញ្ញោភោ **ព្រីង សុវ៉ាន**

២- ឯកឧត្តម **មុន្នី ហោវ៉ាត**

៣- លោក **មុយ ពៅ**

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- ឯកឧត្តម **ហែល សុខា**

២- ឯកឧត្តម **គីម វណ្ណា**

៣- ឯកឧត្តម **ខឹម សុជាត**

៤- ឯកឧត្តម **ស៊ីម យូហុង**

៥- ឯកឧត្តម **លឹម សេង**

៦- ឯកឧត្តម **មិន សោភ័ណ្ឌ**

៧- ឯកឧត្តម **ហ្វូវ ហៀងម៉េង**

៨- ឯកឧត្តម **អាង បូរ៉ា**

៩- លោក **គឹម ភួងច័ន្ទដារ៉ាវិទូ**

១០- ឧបាសិកា **ជី ប៊ុយចៀង**

១១- ឧបាសិកា **ឈុន តាំងសៀក**

១២- ឧបាសក **អឹម ឆន**

**មាត្រា២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/

ថ្ងៃ សុក្រ ៦កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៩៩ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១.**-បំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តឈូសមេត្រី ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល ចំណាយអស់ថវិកាចំនួន ១២៧ ៣៥០ (មួយរយម្ភៃប្រាំពីរពាន់ បីរយហាសិប) ដុល្លារអាម៉េរិកកន្លងមក ដូចមានរាយនាមខាងក្រោមៈ

១- លោកជំទាវ **ជា គន្ធា**

២- លោក **ប្អូន ស៊ីអេង**

៣- ឧបាសក **ជី ធន**

៤- អ្នកស្រី **រីម ម៉ាណារី**

៥- លោក **យាន នៅ**

៦- លោក **សេក ភិន**

៧- លោក **សុខ គង់**

៨- លោក **ចាន់ ថុល**

៩- លោក **លី វ៉សេត**

១០- អ្នកស្រី **ស្មាន អែវណាស់**

១១- លោក **ប៊ូ បូរី**

១២- លោក **ហេង សុផល**

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧០.០.៥៨.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**មាត្រា១.** បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ៧រូប ដែលបានចូលរួមជួយកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុកន្លងមក ដូចមានរាយនាមខាងក្រោមៈ

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

លោក Bui Phong Chau

ខ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- លោក Phan Dinh Thu

២- លោក Pham Van Thang

គ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោកស្រី Nguyen Minh phuong

២ លោក Nguyen Canh Anh Tuan

៣ លោកស្រី Tran Thi Bich Ngoc

៤ លោក Doan Minh Hai

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ ពិសាខ ឆ្នាំខ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣០១ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសហមេត្រី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សម្រេច**

**មាត្រា១.** -បំពាក់មេដាយ**សហមេត្រី** ថ្នាក់**ធិបឌិន្ទ** ជូនលោកបណ្ឌិត **អូលីវីយេ សេហ្សេរ៉ាល់** (Doctor Olivier SEGERAL) ជនជាតិបារាំង ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលដោយជួយបណ្តុះបណ្តាល និងដឹកនាំនិក្ខេបបទដល់និស្សិតនិងបុគ្គលិកកន្លងមក។

**មាត្រា២.** -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងអគ្គនាយក នៃសហគ្រាស គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ស្តីពីការបង្កើតសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **គីម សេត** ឲ្យកាន់មុខតំណែងជាអគ្គនាយក នៃសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ (ស.ស.ភ)។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥១១......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងាររបស់សាមីអគ្គនាយកដ្ឋាន។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៣.-**

អគ្គនាយកដ្ឋានថវិកាបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងថវិកាជាតិ ក្នុងគោលដៅធានាឱ្យមានការបែងចែក និងប្រើប្រាស់ធនធានថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

**ប្រការ៤.-**

អគ្គនាយកដ្ឋានថវិកាមានភារកិច្ចដូចតទៅ ÷

- កសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ជាហិរញ្ញវត្ថុសាធារណៈ
- រៀបចំការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុ បទបញ្ជាហិរញ្ញវត្ថុសាធារណៈ និងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងការងារកសាងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា
- រៀបចំកម្មវិធីចំណាយសាធារណៈទៀងទាត់ ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈ ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំ និងសម្រាប់គម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលបានទទួលការអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ចូលរួមសហការក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ

- រៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សា និងវាយតម្លៃបច្ចេកទេសគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានថវិកាក្នុងប្រទេសថ្នាក់ជាតិ
- សម្របសម្រួល និងណែនាំបច្ចេកទេសដល់ក្រសួង ស្ថាប័ននានាក្នុងក្របខណ្ឌនៃការតាមដាននិងរៀបចំរបាយការណ៍សមិទ្ធកម្ម
- សម្របសម្រួល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័ន អង្គភាពថវិកា ក្នុងការរៀបចំ និងកែលម្អការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ លទ្ធផលចុងក្រោយ និងការរៀបចំកម្មវិធីក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងការឈានទៅអនុវត្តថវិកាសមិទ្ធកម្ម
- ធ្វើការតាមដាន និងវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.-**

អគ្គនាយកដ្ឋានថវិកា មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម ÷

១. នាយកដ្ឋានកិច្ចការទូទៅ

២. នាយកដ្ឋានថវិកានីយកម្ម

៣. នាយកដ្ឋានហិរញ្ញកិច្ច

៤. នាយកដ្ឋានវិនិយោគ

៥. នាយកដ្ឋានតាមដាន និង វាយតម្លៃ។

**ប្រការ៦.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានថវិកា ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៣
## នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៧.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារគ្រប់គ្រងកិច្ចការទូទៅដោយមានតួនាទី និងភារកិច្ច ដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់អគ្គនាយក
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារពិធីការ និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួល និងរៀបចំគម្រោងស្នើសុំថវិកាប្រចាំឆ្នាំ និងទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបុគ្គលិកមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យា របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីប្រជុំទៀងទាត់ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋាន

- រៀបចំនិងគ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋាន
- សម្របសម្រួល និងបូកសរុបលទ្ធផលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ។

**ប្រការ៨.-**

នាយកដ្ឋានកិច្ចការទូទៅ មានការិយាល័យក្រោមឱវាទចំនួន ២ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាល និងបុគ្គលិក

២. ការិយាល័យព័ត៌មានវិទ្យានិងសរុប។

**ប្រការ៩.-**

ការិយាល័យរដ្ឋបាល និងបុគ្គលិកមានភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ-ចូលសម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំលិខិតស្នាមរដ្ឋបាលនិងបោះពុម្ពឯកសារផ្សេងៗ
- ទទួលបន្ទុកការងារពិធីការនិងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- រៀបចំគម្រោងស្នើសុំថវិការបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងបែងចែកសម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងស្ថិតិបុគ្គលិកមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន រាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិ ការលើកយោបល់លើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការរៀបចំប្រាក់បៀវត្ស និងការគាំពារផ្សេងៗ
- គ្រប់គ្រងវត្តមានបុគ្គលិកមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងវត្តមានមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យារបស់អគ្គនាយកដ្ឋាន
- រៀបចំ និងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន។

**ប្រការ១០.-**

ការិយាល័យព័ត៌មានវិទ្យានិងសរុបមានភារកិច្ច ដូចតទៅ÷

- ផ្តល់ការគាំទ្រខាងបច្ចេកទេសព័ត៌មានវិទ្យាដល់នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានថវិកា
- រៀបចំនិងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការរៀបចំ ការដំឡើង និងការថែរក្សាប្រព័ន្ធបណ្តាញ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត នៅក្នុងអគ្គនាយកដ្ឋាន
- រៀបចំនិងបញ្ចូលទិន្នន័យផ្សេងៗ ពាក់ព័ន្ធនឹងចំណាយថវិកាចូលទៅប្រព័ន្ធបណ្តាញ
- បូកសរុបលទ្ធផលការងារ និងរៀបចំរបាយការណ៍ការងារទៀងទាត់របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន។

## ជំពូកទី៤

## នាយកដ្ឋានថវិកានីយកម្ម

**ប្រការ១១.-**

នាយកដ្ឋានថវិកានីយកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារថវិកានីយកម្ម ដោយមានភារកិច្ចដូចតទៅ÷

- ដឹកនាំនិងសម្របសម្រួលកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រួមទាំងការរៀបចំសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ, សារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកាសម្រាប់ឆ្នាំនីមួយៗ
- រៀបចំកញ្ចប់តួលេខចំណូល និងចំណាយដំបូងរបស់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈ
- ចូលរួមរៀបចំគោលនយោបាយចំណាយថវិកា ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ចូលរួមក្នុងដំណើរការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងក្នុងការកសាងតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែ
- រៀបចំក្របខណ្ឌថវិការយៈពេលមធ្យម
- ដឹកនាំការរៀបចំកម្មវិធីចំណូល និងចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីអនុវត្ត
- ដឹកនាំការធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ និងប្រាំបួនខែដើមឆ្នាំ និងការវាយតម្លៃលទ្ធផលប៉ាន់ស្មាននៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល
- បូកសរុបការអនុវត្តនិងប៉ាន់ស្មានការអនុវត្តថវិកាប្រចាំឆ្នាំ
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិការបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមរៀបចំវេទិកាសាធារណៈពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល លើការរៀបចំ និងអនុវត្តថវិកា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ។

**ប្រការ១២.-**

នាយកដ្ឋានថវិកានីយកម្ម មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងសរុបថវិកា
២. ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ
៣. ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
៤. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១
៥. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២
៦. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១
៧. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២។

**ប្រការ១៣.-**

ការិយាល័យរដ្ឋបាលនិងសរុបថវិកា មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន

- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- សម្របសម្រួលគ្រប់ការិយាល័យចំណុះនាយកដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំថវិកា តាមដានការអនុវត្តថវិកា និងប្រមូលផ្តុំទិន្នន័យចំណូលនិងចំណាយថវិកា
- សម្របសម្រួលកិច្ចដំណើរការបច្ចេកទេសដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- សម្របសម្រួលការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- រៀបចំរបាយការណ៍ស្តីពីការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ និងប្រាំបួនខែដើមឆ្នាំ និងវាយតម្លៃលទ្ធផលប៉ាន់ស្មាន នៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើប្រាស់ឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

**ប្រការ១៤.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងព្រះបរមរាជវាំង, រដ្ឋសភា, ព្រឹទ្ធសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងមុខងារសាធារណៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងផែនការ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១៥.-**

ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងយុត្តិធម៌, តុលាការកំពូល, សាលាឧទ្ធរណ៍ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ១៦.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងព័ត៌មាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, និង ក្រសួងធម្មការនិងសាសនា។

**ប្រការ១៧.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងសុខាភិបាល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

**ប្រការ១៨.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល។

**ប្រការ១៩.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលរួមមាន÷ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងប្រៃសណីយ៍

និងទូរគមនាគមន៍, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ២០.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ និង ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត
- សហការក្នុងកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- សហការរៀបចំសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- រៀបចំតួលេខត្រួតពិនិត្យចំណូល-ចំណាយថវិកាឱ្យក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដើម្បីអនុវត្ត
- សហការជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកសាងផែនការថវិកាប្រចាំឆ្នាំរបស់មន្ទីរជំនាញរាជធានី ខេត្ត
- សហការក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- កត់ត្រា តាមដានជាប្រចាំនិងទៀងទាត់ លើការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យនិងផ្តល់យោបល់ លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន, មន្ទីរជំនាញ រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បូកសរុបរបាយការណ៍អនុវត្តថវិកា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- សហការក្នុងកិច្ចដំណើរការបច្ចេកទេសរៀបចំវេទិកាសាធារណៈពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលលើការរៀបចំថវិកា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

## ជំពូកទី៥
## នាយកដ្ឋានហិរញ្ញកិច្ច

**ប្រការ២១.-**

នាយកដ្ឋានហិរញ្ញកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារហិរញ្ញកិច្ច ដោយមានភារកិច្ច ដូចតទៅ ÷

- អនុវត្តការងារត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុវត្តការងារពាក់ព័ន្ធបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- គ្រប់គ្រងសកម្មភាព សម្របសម្រួល និងតាមដានការអនុវត្តរបស់អភិបាលហិរញ្ញវត្ថុ
- កត់ត្រាជាប្រចាំ និងបូកសរុបទៀងទាត់នូវការសន្យាចំណាយ
- ពិនិត្យ និងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើសំណើសុំចំណាយថវិការបស់ក្រសួង ស្ថាប័ន និង គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ត្រួតពិនិត្យការអនុវត្តចំណាយថវិការបស់ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់

- ពិនិត្យ និងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើ សំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័ន និង គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្តល់យោបល់បច្ចេកទេសដល់អាណាប័ក ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង រៀបចំបទបញ្ញាហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយដ្ឋានថវិកា ។

**ប្រការ២២.-**

នាយកដ្ឋានហិរញ្ញកិច្ច មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ

៣. ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៤. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១

៥. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២

៦. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១

៧. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២។

**ប្រការ២៣.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្តុំទិន្នន័យ ពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យគ្រប់គ្រងហិរញ្ញកិច្ច ស្តីពីការអនុវត្ត ថវិការដ្ឋ ដែលមានជាអាទិ៍ របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- សម្របសម្រួលការកសាងនីតិវិធី និងបទដ្ឋានចំណាយផ្សេងៗ សម្រាប់អនុវត្តជាទូទៅ
- ចូលរួមរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

**ប្រការ២៤.-**

ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ក្រសួងព្រះបរមរាជវាំង, រដ្ឋសភា, ព្រឹទ្ធសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងមុខងារសាធារណៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងការបរទេសនិងសហប្រតិបត្តិការ

អន្តរជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងផែនការ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ២៥.-**

ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ, និងក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និង ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ២៦.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន ÷ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងព័ត៌មាន និង ក្រសួងធម្មការ និងសាសនា។

**ប្រការ២៧.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងសុខាភិបាល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

**ប្រការ២៨.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងរ៉ែនិងថាមពល។

**ប្រការ២៩.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងសាធារណការនិងដឹកជញ្ជូន,ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ៣០.-**

ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ, ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១, ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២, ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ និងការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ ÷

- តាមដាន និងសម្របសម្រួលសកម្មភាពអនុវត្តរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- ប្រមូលផ្តុំព័ត៌មាន និងទិន្នន័យនៃការសន្យាចំណាយ ការប្រើប្រាស់ឥណទានថវិកា និងការបញ្ចេញអាណត្តិបើកប្រាក់
- ធ្វើសំយោគរបាយការណ៍របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ស្តីពីការអនុវត្តចំណាយថវិការដ្ឋ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការប្រតិបត្តិនៃកិច្ចសន្យាគម្រោង ដើម្បីលើកយោបល់អំពីវិធានការចាំបាច់ដែលត្រូវធ្វើការកែលម្អ កែទម្រង់ សំដៅលុបបំបាត់កង្វះខាតទាំងឡាយ ដែលកត់សម្គាល់ឃើញជាយថាហេតុ

- ចូលរួមក្នុងការរៀបចំកម្មវិធីចំណូល-ចំណាយថវិកាប្រចាំខែ ត្រីមាស និងតាមដានការអនុវត្តកម្មវិធីនេះ ឱ្យបានខ្ជាប់ខ្ជួន
- ចូលរួម និងសិក្សាអំពីតម្រូវការចំណាយនានារបស់ក្រសួង ស្ថាប័ន និង គ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ និងសម្រាប់ការរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

**ប្រការ៣១.-**

នាយកដ្ឋានហិរញ្ញកិច្ច មានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នៅអមក្រសួង ស្ថាប័ននីមួយៗ ដែលអាចមានចំនួនមួយរូប ឬច្រើនរូប។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ ឋានៈស្មើអនុប្រធានការិយាល័យ។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣២.-**

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យការអនុវត្តចំណាយថវិការបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងប្រសិទ្ធភាព ភាពចាំបាច់ និងភាពត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង ក្នុងការផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្តល់ប្រឹក្សាជាប្រចាំ អំពីនីតិវិធីចំណាយ ចំពោះផ្នែកនានារបស់អាណាប័ក
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- កាន់កាប់បញ្ជីគណនេយ្យសន្យាចំណាយ និងអាណត្តិកិច្ចតាមលក្ខខណ្ឌ ដូចខាងក្រោម÷
  - គណនេយ្យចំណាយវលញ្ជិក សម្រាប់ចំណាយចុះកិច្ចសន្យា
  - គណនេយ្យចំណាយអាណាប័ណ្ណ សម្រាប់អាណត្តិបើកប្រាក់។

## ជំពូកទី៦

## នាយកដ្ឋានវិនិយោគ

**ប្រការ៣៣.-**

នាយកដ្ឋានវិនិយោគ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារវិនិយោគ ដោយមានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម សម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- គ្រប់គ្រងឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង រៀបចំបទបញ្ញាហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការវិនិយោគសាធារណៈ និងផែនការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- សិក្សា និងវាយតម្លៃបច្ចេកទេសលើគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- រៀបចំគោលការណ៍កំណត់អាទិភាពគម្រោង និងបញ្ជីអាទិភាពគម្រោង សម្រាប់គោលបំណងថវិកានីយកម្មប្រចាំឆ្នាំនៃគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំកម្មវិធីចំណាយជាទៀងទាត់ សម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងសម្រាប់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ របស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលបានទទួលការអនុម័តរួច
- ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើសំណើសុំចំណាយ និងបុរេប្រទានថវិកាគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ របស់ក្រសួង ស្ថាប័ន
- ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការប្រើឥណទានថវិកាមិនទាន់បែងចែក សម្រាប់គម្រោងវិនិយោគផ្ទាល់
- ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំធ្វើនិយ័តភាពថវិកាគម្រោងវិនិយោគផ្ទាល់ ជូនក្រសួង ស្ថាប័ន តាមការចាំបាច់
- ចូលរួមសហការក្នុងការត្រួតពិនិត្យនិងតាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងវាយតម្លៃលទ្ធផលការងាររបស់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួល ទិនិញ សំណង់ និងសេវាកម្ម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា។

**ប្រការ៣៤.-**

នាយកដ្ឋានវិនិយោគមានការិយាល័យក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១

៣. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២

៤. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣

៥. ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

**ប្រការ៣៥.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់នាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្ដុះបណ្ដាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួល និងប្រមូលផ្ដុំទិន្នន័យពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យជំនាញ ស្ដីពីការអនុវត្តថវិការដ្ឋ ដែលមានជាអាទិ៍ របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- គ្រប់គ្រងឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- បូកសរុបរបាយការណ៍ចំណាយ និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតរបស់នាយកដ្ឋាន
- សម្របសម្រួលគ្រប់ការិយាល័យចំណុះនាយកដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំថវិកា តាមដានការអនុវត្តថវិកា និងប្រមូលផ្ដុំទិន្នន័យចំណាយថវិកា
- សម្របសម្រួលការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន
- រៀបចំកម្មវិធីចំណាយជាទៀងទាត់ សម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ និងគម្រោងថែទាំហេដ្ឋារចនា-សម្ព័ន្ធរូបវន្តសាធារណៈ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន។

**ប្រការ៣៦.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ទីស្ដីការគណៈរដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងមុខងារសាធារណៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងធម្មការនិងសាសនា, ក្រសួងកិច្ចការនារី, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអាជ្ញាធរសវនកម្មជាតិ។

**ប្រការ៣៧.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងព្រះបរមរាជវាំង, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងពាណិជ្ជកម្ម, ក្រសួងព័ត៌មាន, ក្រសួងទេសចរណ៍, ក្រសួងបរិស្ថាន, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងរ៉ែនិងថាមពល, ក្រសួងផែនការ, រដ្ឋសភា, ព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ។

**ប្រការ៣៨.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។

**ប្រការ៣៩.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ និងការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម សម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ
- គ្រប់គ្រងឥណទានថវិកាគម្រោងវិនិយោគផ្ទាល់
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងរៀបចំបទបញ្ញាហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការវិនិយោគសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- សិក្សា និងវាយតម្លៃបច្ចេកទេសលើគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ
- រៀបចំគោលការណ៍កំណត់អាទិភាពគម្រោងសម្រាប់គោលបំណងថវិកានីយកម្មប្រចាំឆ្នាំ នៃគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ របស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលបានទទួលការអនុម័តរួច
- ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើសំណើសុំចំណាយ និងបុរេប្រទានថវិកាគម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ
- ចូលរួមសហការក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងវាយតម្លៃលទ្ធផលការងាររបស់គម្រោងវិនិយោគសាធារណៈថ្នាក់ជាតិ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ និងរបាយការណ៍ផ្សេងៗទៀតជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ៤០.-**

ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម សម្រាប់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- គ្រប់គ្រងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងរៀបចំបទបញ្ញាហិរញ្ញវត្ថុសាធារណៈពាក់ព័ន្ធ

- រៀបចំអាទិភាពគម្រោងប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មនៃគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សា និងវាយតម្លៃបច្ចេកទេសលើគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ របស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលបានទទួលការអនុម័តរួច
- ពិនិត្យនិងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើសំណើសុំចំណាយ និងបុរេប្រទានថវិកាគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ របស់ក្រសួង ស្ថាប័ន
- ចូលរួមសហការក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ របស់ក្រសួង ស្ថាប័ន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងវាយតម្លៃលទ្ធផលការងាររបស់គម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ និងរបាយការណ៍ផ្សេងៗទៀតជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

## ជំពូកទី៧

## នាយកដ្ឋានតាមដាន និងវាយតម្លៃ

**ប្រការ៤១.-**

នាយកដ្ឋានតាមដាន និងវាយតម្លៃ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារតាមដាន និងវាយតម្លៃសមិទ្ធកម្ម ដោយមានភារកិច្ចដូចតទៅ ÷

- សម្របសម្រួល និងណែនាំបច្ចេកទេសដល់ក្រសួង ស្ថាប័ននានា ក្នុងក្របខណ្ឌនៃការតាមដាន និងរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធី
- សម្របសម្រួល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័ន អង្គភាពថវិកា ក្នុងការរៀបចំ និងកែលម្អការកំណត់សូចនាករសមិទ្ធកម្មគន្លឹះនៃលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ព្រមទាំងរចនាសម្ព័ន្ធកម្មវិធី ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងការឈានទៅអនុវត្តថវិកាសមិទ្ធកម្ម
- ពិនិត្យវាយតម្លៃ បូកសរុប និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើរបាយការណ៍តាមដានការអនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្មរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ។

**ប្រការ៤២.-**

នាយកដ្ឋានតាមដាន និងវាយតម្លៃមានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យតាមដានសមិទ្ធកម្មទី ១

៣. ការិយាល័យតាមដានសមិទ្ធកម្មទី ២

៤. ការិយាល័យវាយតម្លៃសមិទ្ធកម្ម

**ប្រការ៤៣.-**

**ការិយាល័យរដ្ឋបាលនិងសរុប** មានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- រៀបចំសំណើសុំថវិការបស់នាយកដ្ឋាន
- ជាកន្លែងគ្រប់គ្រងប្រព័ន្ធទិន្នន័យតាមដាន និងវាយតម្លៃ
- រៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងប្រជុំពាក់ព័ន្ធ
- បូកសរុបរបាយការណ៍ចំណាយ និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតរបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- សម្របសម្រួលការងារតាមដាន និងការងារវាយតម្លៃសមិទ្ធកម្មថ្នាក់ជាតិ
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

**ប្រការ៤៤.-**

**ការិយាល័យតាមដានសមិទ្ធកម្មទី១** ទទួលបន្ទុកការងារតាមដានសមិទ្ធកម្មក្នុងក្របខណ្ឌនៃការអនុវត្តថវិកាសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន រួមទាំងអង្គភាព និងមន្ទីរជំនាញក្រោមឱវាទ ស្ថិតនៅក្នុងចង្កោមនៃថវិកាវិស័យសង្គមកិច្ច និងថវិកាវិស័យរដ្ឋបាលទូទៅ ។

**ប្រការ៤៥.-**

**ការិយាល័យតាមដានសមិទ្ធកម្មទី២** ទទួលបន្ទុកការងារតាមដានសមិទ្ធកម្មក្នុងក្របខណ្ឌនៃការអនុវត្តថវិកាសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន រួមទាំងអង្គភាព និងមន្ទីរជំនាញក្រោមឱវាទ ស្ថិតនៅក្នុងចង្កោមនៃថវិកាវិស័យសេដ្ឋកិច្ច និងថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**ប្រការ៤៦.-**

ការិយាល័យតាមដានសមិទ្ធកម្មទី១ និងការិយាល័យសមិទ្ធកម្មទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័នរួមទាំងអង្គភាព និងមន្ទីរជំនាញក្រោមឱវាទ ដោយមានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ណែនាំក្រសួង ស្ថាប័ន រៀបចំគោលការណ៍ណែនាំ ស្តង់ដា និងបទដ្ឋាននានាពាក់ព័ន្ធនឹងការតាមដានសមិទ្ធកម្ម
- ណែនាំក្រសួង ស្ថាប័ន រៀបចំក្របខណ្ឌតាមដានសមិទ្ធកម្មទៅតាមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន

- ពិនិត្យ និងផ្តល់សុពលភាពលើក្របខណ្ឌតាមដានសមិទ្ធកម្ម ដែលរៀបចំឡើងតាមកម្មវិធីនីមួយៗរបស់ក្រសួង ស្ថាប័ន
- វិភាគលើសុពលភាពទិន្នន័យស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនីមួយៗ របស់ក្រសួង ស្ថាប័ន
- ពិនិត្យ និងបញ្ជាក់អនុលោមភាពលើរបាយការណ៍សមិទ្ធកម្មនៃកម្មវិធីនីមួយៗរបស់ក្រសួង ស្ថាប័ន
- តាមដានលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម
- សិក្សាស្រាវជ្រាវ និងពង្រឹងសមត្ថភាពការងារពាក់ព័ន្ធនឹងការតាមដានសមិទ្ធកម្ម
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាពាក់ព័ន្ធក្រោមសមត្ថកិច្ចរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

**ប្រការ៤៧.-**

ការិយាល័យវាយតម្លៃសមិទ្ធកម្ម ទទួលបន្ទុកការងារពាក់ព័ន្ធនឹងការវាយតម្លៃសមិទ្ធកម្មកម្រិតកម្មវិធី របស់ក្រសួង ស្ថាប័ន ដោយមានតួនាទី និងភារកិច្ច ដូចតទៅ ÷

- រៀបចំគោលការណ៍ណែនាំ ស្តង់ដា និងបទដ្ឋាននានាពាក់ព័ន្ធនឹងការវាយតម្លៃសមិទ្ធកម្ម
- រៀបចំក្របខណ្ឌការវាយតម្លៃលើលទ្ធផលសម្រេចបានរបស់ក្រសួង ស្ថាប័ន តាមការជ្រើសរើស និងដោយមានការឯកភាពរបស់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើការវាយតម្លៃសមិទ្ធកម្មកម្រិតគោលនយោបាយ និងកម្រិតយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- រៀបចំ ឬត្រួតពិនិត្យ និងផ្តល់អនុលោមភាពលើលក្ខខណ្ឌបច្ចេកទេស (TOR) វាយតម្លៃសមិទ្ធកម្មដែលអនុវត្តដោយតួអង្គខាងក្រៅ ព្រមទាំងចូលរួមជ្រើសរើសអង្គភាពវាយតម្លៃផ្នែកក្រៅ តាមនីតិវិធីជាធរមាន
- ពិនិត្យលើស្តង់ដារ និងគុណភាពនៃការអនុវត្តការវាយតម្លៃ និងលទ្ធផលនៃការវាយតម្លៃដោយតួអង្គខាងក្រៅ
- សិក្សាស្រាវជ្រាវ និងពង្រឹងសមត្ថភាពការងារពាក់ព័ន្ធនឹងការវាយតម្លៃសមិទ្ធកម្ម
- រៀបចំការបណ្តុះបណ្តាល និងសិក្ខាសាលា ពាក់ព័ន្ធក្រោមសមត្ថកិច្ចរបស់ខ្លួន
- ប្រើប្រាស់ព័ត៌មានដែលទទួលបានពីការអនុវត្តការតាមដាន និងវាយតម្លៃរបស់ក្រសួង ស្ថាប័ន និងប្រមូលព័ត៌មានចំបាច់ពីប្រភពផ្សេងទៀត សម្រាប់ការវិភាគថ្លៃដើម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាននាយកដ្ឋាន ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៤៨.-**

ក្នុងពេលបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៤៩.-**

ប្រកាសនេះ មានអានុភាពអនុវត្តជំនួសប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៥០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## អង្គការលេខនៃអគ្គនាយកដ្ឋានថវិកា

ឧបសម្ព័ន្ធទី១
នៃប្រកាសលេខ ៤១១ សហវ.ប្រក
ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការ
រៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិង
អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



## ឧបសម្ព័ន្ធទី២

## នៃប្រកាសលេខ ៤១១ សហវ.ប្រក ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២២ ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ

## អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានដូចតទៅ÷

១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព្រះបរមរាជវាំង

២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ព្រឹទ្ធសភា

៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋសភា

៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាធម្មនុញ្ញ

៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អាជ្ញាធរសវនកម្មជាតិ

៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ទីស្តីការគណៈរដ្ឋមន្ត្រី

៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមុខងារសាធារណៈ

៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

១០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងយុត្តិធម៌

១១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

១៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងផែនការ

១៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ

១៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការពារជាតិ

១៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

១៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទេសចរណ៍

២០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអភិវឌ្ឍន៍ជនបទ

២៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធនធានទឹក និងឧតុនិយម
២៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសាធារណការ និងដឹកជញ្ជូន
២៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងពាណិជ្ជកម្ម
២៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
២៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
២៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព័ត៌មាន
៣០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងបរិស្ថាន
៣១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសុខាភិបាល
៣២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអប់រំ យុវជន និងកីឡា
៣៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៣៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធម្មការ និងសាសនា
៣៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកិច្ចការនារី
៣៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៣៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អង្គភាពប្រឆាំងអំពើពុករលួយ
៣៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងរ៉ែ និងថាមពល។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤១៦ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធន ដល់អ្នកវិនិយោគមូលបត្ររដ្ឋ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធនិងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- បានឃើញប្រកាសលេខ ១៧៨ សហវ.ប្រក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ ស្តីពីការបោះផ្សាយមូលបត្ររដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ និងពន្ធលើចំណេញមូលធនសម្រាប់ប្រតិបត្តិការមូលបត្ររដ្ឋ។

**ប្រការ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកវិនិយោគដែលកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.- ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធន ដល់អ្នកវិនិយោគមូលបត្ររដ្ឋ**

អ្នកវិនិយោគត្រូវបានទទួលការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ សម្រាប់រយៈពេល ៣ (បី) ឆ្នាំ ដោយអនុលោមតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

អ្នកវិនិយោគត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្រ។

**ប្រការ៤.- អត្រាពន្ធកាត់ទុកលើការប្រាក់នៃមូលបត្ររដ្ឋ**

ពន្ធកាត់ទុកលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់តាមអត្រាដូចខាងក្រោម÷

ក. អត្រា ៦ (ប្រាំមួយ) ភាគរយ ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ដូចគ្នានឹងការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ស្របតាមមាត្រា២៥ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

ខ. អត្រា ១៤ (ដប់បួន) ភាគរយ ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន។

ភ្នាក់ងារកាត់ទុកត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកមុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ពន្ធកាត់ទុកទៅតាមទម្រង់ជូនរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០(ម្ភៃ) នៅខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

**ប្រការ៥.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១៧៥៤ ឧវប.........ភក.........

ថ្ងៃ.......................ខែ.......... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០..... ខែ.......... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០០៦/១៨ ស.ហ.ត.ស.ព ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតសម្ភារៈវេចខ្ចប់ កេសក្រដាសកាតុង ប្រអប់ឬថង់ផ្លាស្ទិក និងបោះពុម្ពលើសម្ភារៈវេចខ្ចប់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ហេ យី ថេកណូឡូជី (ខេមបូឌា) ព្រីនធីង & ផែកឃិជីង ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហេ យី ថេកណូឡូជី (ខេមបូឌា) ព្រីនធីង & ផែកឃិជីង ឯ.ក (**HE YI TECHNOLOGY (CAMBODIA) PRINTING & PACKAGING CO., LTD.**) តំណាងដោយលោក **CHEN, CHENG-HO** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ **310289507** ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ បង្កើតរោងចក្រផលិតសម្ភារវេចខ្ចប់ កេសក្រដាសកាតុង ប្រអប់ ថង់ផ្លាស្ទិក និងបោះពុម្ពលើសម្ភារវេចខ្ចប់ ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសស្វាយរៀង ហ្គីហ្គា ស៊ែរ (ភូមិជើងពោធិ៍ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង)។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១-កេសកាតុង | ១៧០២ |
| ២-ថង់ប្លាស្ទិក | ២២២០ |
| ៣-សម្ភារវេចខ្ចប់ (បោះពុម្ព) | ១៨១១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រផលិតសម្ភារវេចខ្ចប់ កេសក្រដាសកាតុង ប្រអប់ ថង់ប្លាស្ទិក និងបោះពុម្ពលើសម្ភារវេចខ្ចប់ ហេ យី ថេកណូឡូជី (ខេមបូឌា) ព្រីនធីង & កែកឃិជីង ឯ.ក**"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៤១៨ ឧស.កឧ.ប្រក.១២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តស្វាយរៀង
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
- -អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស្វាយរៀង ហ្គីហ្គា រីសស៍
- -រដ្ឋបាលស្រុកស្វាយទាប
- -រដ្ឋបាលឃុំកណ្តៀងរាយ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ ១៩៥ ............ ថ្ងៃ សុក្រ ៥កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីជូនដំណឹងលេខ៩០៧/២២ ក.អ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតឥដ្ឋការ៉ូគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតឥដ្ឋការ៉ូគ្រប់ប្រភេទ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន រ៉ុង ជីន ស៊ី ស៊ី សេរ៉ាមិច ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន រ៉ុង ជីន ស៊ី ស៊ី សេរ៉ាមិច ឯ.ក **(RONG JIN C C CERAMIC CO., LTD.)** តំណាងដោយលោក **PAN, DAOXIN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EH4789369** ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បង្កើតរោងចក្រផលិតឥដ្ឋការ៉ូគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅភូមិអូរក្រាំ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ឥដ្ឋការ៉ូគ្រប់ប្រភេទ | ២៣៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតឥដ្ឋការ៉ូគ្រប់ប្រភេទ រ៉ុង ជីន ស៊ី ស៊ី សេរ៉ាមិច ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុគា

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
-រដ្ឋបាលស្រុកព្រៃនប់
-រដ្ឋបាលឃុំអណ្តូងថ្ម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ១០៤០/២២ ក.អ.ក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ម៉ាឡាហ្គា ហ្គាម៉ិន ហ្វេកធើរី ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ម៉ាឡាហ្គា ហ្គាម៉ិន ហ្វេកធើរី ឯ.ក (MALAGA GARMENT FACTORY CO., LTD.)** តំណាងដោយលោក **WANG, HAOJIE** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **G62046071** ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅភូមិ**ព្រែកកំពឹស សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ។**

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| | |
|---|---|
| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **" រោងចក្រកាត់ដេរសម្លៀកបំពាក់ ម៉ាឡាហ្គា ហ្គាមិន ហ្វេកធើរី ឯ.ក "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌដង្កោ
-រដ្ឋបាលសង្កាត់ព្រែកកំពឹស
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១៨៧ ...ឧវ.ក.... ប្រ.ក

ថ្ងៃ........................ ខែ.............. ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ.............. ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីជូនដំណឹងលេខ៨៦៩/២២ ក.អ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន យ៉ុន តឺ ហ្គាម៉ិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុន តឺ ហ្គាម៉ិន ឯ.ក (YUN TER GARMENT CO., LTD.) តំណាងដោយលោក **ម៉ែន សារ៉ា** សញ្ជាតិខ្មែរ កាន់លិខិតឆ្លងដែនលេខ030957298 ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅភូមិស្នោទី១ សង្កាត់កោរ៉េ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
